# គម្រោងវប្បធម៌ «KUSANONE» របស់ជប៉ុនបាន ចាប់ផ្តើមជាលើក ដំបូងនៅកម្ពុជា

គម្រោងវប្បធម៌«KUSANONE» លើកដំបូង ដើម្បីជួយដល់ប្រទេសកម្ពុជា នៅក្នុងការថែរក្សាសម្បត្តិវប្បធម៌របស់ខ្លួនត្រូវបានអនុម័តនិងចុះហត្ថលេខាផ្តល់ជំនួយដោយឯកអគ្គរដ្ឋទូតជប៉ុនប្រចាំនៅប្រទេសកម្ពុជា លោកហ្គោកាវ៉ូអ៊ូហ្គាវ៉ា និងលោកយ៉ូស៊ីយ៉ាគីអ៊ីស៊ីហ្សាវ៉ា ប្រធានបេសកកម្មអន្តរជាតិអង្គរនៃសកលវិទ្យាល័យសូហ្វីយ៉ាកាល ពីថ្ងៃទីមួយម៉ិនា។ ការផ្តល់ជំនួយដល់គម្រោងប្រាំទៀតដើម្បីជួយអភិវឌ្ឍន៍ប្រទេសកម្ពុជា ក៏ត្រូវបានគេចុះហត្ថលេខាផងដែរ នៅឯស្ថានទូតជប៉ុនកាលពីម្សិលមិញ ។ គម្រោងទាំង៦នេះមានតម្លៃជាទឹកប្រាក់ជាសរុបចំនួន ៣៣៣.៧៧៣ដុល្លារ ។

លោកឯកអគ្គរដ្ឋទូតជប៉ុន ហ្គោកាវ៉ូអ៊ូហ្គាវ៉ាបាននិយាយមុនពេលចុះហត្ថលេខាផ្តល់ជំនួយថា គម្រោង «KUSANONE»នេះមានបំណងព្យាយាមជួយដល់ប្រជាជនសាមញ្ញធម្មតា »។ លោកទូតបានបញ្ជាក់ទៀតថា «ខ្ញុំមានការសប្បាយចិត្តណាស់ដែលបានចុះហត្ថលេខានៅក្នុងការផ្តល់ជំនួយដល់គម្រោងទាំង៦នេះ»។ គម្រោងផ្តល់ជំនួយតាមរយៈគម្រោង«KUSANONE»បានកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ កម្មវិធីផ្តល់ជំនួយមួយចំនួនទៀតនឹងត្រូវ

នេះគឺជាលើកដំបូងហើយដែលគម្រោង«KUSANONE»សម្រាប់ផ្នែកវប្បធម៌ត្រូវបានគេអនុម័តឡើង ។ គម្រោងវប្បធម៌នេះមានតម្លៃជាទឹកប្រាក់ចំនួន៦២.៧១៩ដុល្លារ ហើយត្រូវបានផ្តល់ឱ្យអង្គការបេសកកម្មអន្តរជាតិអង្គរនៃសកលវិទ្យាល័យសូហ្វីយ៉ា ដើម្បីជួយលើកកម្ពស់ប្រសិទ្ធភាពនៅក្នុងការងារសម្រាប់ការស្តារឡើងវិញ កេរ្តិ៍ដំណែលវប្បធម៌និងសមត្ថភាពនៅក្នុងការរកព័ត៌មាន ។ គម្រោងវប្បធម៌«KUSANONE»នឹងផ្តល់ឱ្យម៉ាស៊ីនស្ទូចមួយនិងឧបករណ៍ស្ទង់មួយគ្រឿងដល់បេសកកម្មអន្តរជាតិអង្គរនៃសកលវិទ្យាល័យសូហ្វីយ៉ា ។ ចំណែកឯគម្រោងប្រាំទៀត ដែលត្រូវបានគេចុះហត្ថលេខាកាលពីថ្ងៃទី២៨កុម្ភៈ រួមមាន: គម្រោងដើម្បីស្តារឡើងវិញប្រព័ន្ធធារាសាស្ត្រនៃអាងទឹកកំពង់ពួយនៅក្នុងខេត្តបាត់ដំបង គម្រោងកសាងសាលារៀនមួយខ្នងនៅសាលាបឋមសិក្សាអាំងខ្មៅ ក្នុងខេត្តកំពង់ស្ពឺ,គម្រោងរៀបចំសិក្ខាសាលាស្តីពីការត្រៀមរៀបចំសម្រាប់ស្ថានភាពអាសន្នដើម្បីគាំទ្រដល់សុខភាពសត្វកម្មវិធីផលិតកម្មនៅក្នុងខេត្តស្វាយរៀង គម្រោងគាំទ្រស្ត្រីនិងកុមារនៅខេត្តបាត់ដំបង និងគម្រោងស្តារផ្លូវចូលនៃអាងទឹកស្វាយខមនៅក្នុងខេត្តតាកែវ ។

គួររំលឹកថាគម្រោងជំនួយឥតសំណង«KUSANONE» របស់ប្រទេសជប៉ុន បានចាប់ផ្តើមនៅក្នុងប្រទេសកម្ពុជាកាលពីឆ្នាំ១៩៩២ ដើម្បីជួយដល់កិច្ចខិតខំអភិវឌ្ឍន៍និងស្តារប្រទេសកម្ពុជានៅក្នុងកម្រិតប្រជាជនសាមញ្ញ ។ បើយោងទៅតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតជប៉ុន បានឱ្យដឹងថា:រហូតមកទល់ពេលនេះជំនួយជាសរុបជិត៩លានដុល្លារត្រូវបានផ្តល់ឱ្យដោយរដ្ឋាភិបាលជប៉ុនតាមរយៈគម្រោង«KUSANONE»ដើម្បីជួយដល់គម្រោងរបស់អាជ្ញាធរក្នុងស្រុក អង្គការរដ្ឋមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិចំនួន១១៧ ជាពិសេសនៅ